ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១៨៥..........................ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការបង្កើតមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ០៧២/១១ ក.ប/ប្រ.ក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាមសំណើរបស់លោកនាយកមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១

## សម្រេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតឱ្យបង្កើតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយដែលមានឈ្មោះថា "មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ" ហៅកាត់ថា "ម.ម.ក.ក" ជាភាសាអង់គ្លេស "CAMBODIA KOREA FRIENDSHIP CENTER" ហៅកាត់ថា "C.K.F.C" ។ មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅផ្ទះលេខ១៥១៥ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ ២ :** មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ បណ្តុះបណ្តាលថ្នាក់វិញ្ញាបនបត្រសិក្សារយៈពេលក្រោម១ឆ្នាំ មានជំនាញភាសាកូរ៉េ។ ទៅអនាគតមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ អាចតម្លើងកម្រិតបណ្តុះបណ្តាល និងជំនាញផ្សេងៗទៀតតាមការរីកចម្រើនរបស់មជ្ឈមណ្ឌលដោយសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៣ :** លក្ខខណ្ឌទទួលសិស្សចូលរៀន៖ បេក្ខជនជាសិក្ខាកាម-សិស្ស-និស្សិត-ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ។

**ប្រការ ៤ :** មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ ដឹកនាំដោយនាយក០១រូប និងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ ៥ :** នាយកមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ មានភារកិច្ច៖

- ជ្រើសរើស សិស្ស សិក្ខាកាម ចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបម្រើការងារ។
- គ្រប់គ្រងឱ្យបានល្អនូវការបង្រៀន ការអនុវត្តន៍ជាក់ស្តែង ការសិក្សា ការប្រឡង និងការប្រគល់វិញ្ញាបនបត្រ។
- គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍រាល់សកម្មភាពបណ្តុះបណ្តាលជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ) ប្រចាំវគ្គនីមួយៗ ប្រចាំត្រីមាស ប្រចាំឆមាសឱ្យបានទៀងទាត់។

**ប្រការ ៦ :** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល និងមានសិទ្ធិបិទក្នុងករណីមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ នេះអនុវត្តខុសពីច្បាប់រដ្ឋ។

**ប្រការ ៧ :** សិស្សដែលបានរៀនចប់កម្មវិធីសិក្សារបស់មជ្ឈមណ្ឌលនេះ ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រតាមជំនាញដែលបានសិក្សា។ វិញ្ញាបនបត្រនេះត្រូវផ្តល់ឱ្យដោយមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ ហើយត្រូវទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីមជ្ឈមណ្ឌលនេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៨ :** មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ មានក្រុមប្រឹក្សាបច្ចេកទេសដែលមានសមាសភាព ០៣រូប៖

| | |
|---|---|
| ១-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-នាយកមជ្ឈមណ្ឌល | អនុប្រធាន |
| ៣-តំណាងសាស្ត្រាចារ្យ ០១រូប | សមាជិក |

**ប្រការ ៩ :** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងនាយកមជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ។

**ប្រការ ១០ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

វង សូត

<u>ចម្លងជូន</u>

-សាលារាជធានីភ្នំពេញ

"ដើម្បីជ្រាបជាព័ត៌មាន"

-មជ្ឈមណ្ឌលមិត្តភាពកម្ពុជា កូរ៉េ

"ដើម្បីអនុវត្ត"

-ដូចប្រការ ៩

-ឯកសារ ខ.ត.ក.អ.ប.វ

-កាលប្បវត្តិ